ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៧៥ សហវ.ប្រ.[illegible]

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យដំណើរការប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃទី១១ មីនា ២០២៤ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញប្រកាសលេខ ៥៤២ សហវ.ប្រក ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញប្រកាសលេខ ៧២៣ សហវ.ប្រក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ស្តីពីវិធាននៃការប្រើប្រាស់វិក្កយបត្រ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងដាក់ឱ្យប្រើប្រាស់ជាផ្លូវការប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា "ហៅកាត់ថា **ប.វ.អ.**" ដើម្បីធានានូវការគ្រប់គ្រងដំណើរការ ត្រួតពិនិត្យ តាមដាន នៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជាប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព គណនេយ្យភាព។

**ប្រការ ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់ប្រតិបត្តិការវិក្កយបត្រ នៃ **ប.វ.អ.** ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់និយមន័យ ដូចមានក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ ៤.-**

**អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល** នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រង ប្រតិបត្តិ ត្រួតពិនិត្យ និងតាមដាន **ប.វ.អ.** ដែលមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង ប្រតិបត្តិ និងតាមដានដំណើរការ **ប.វ.អ.** ជាប្រចាំ
- សម្របសម្រួល និងផ្តល់ព័ត៌មានអំពីការចុះឈ្មោះចូលជាសមាជិកនៃ **ប.វ.អ.** ជូនភាគីដែលពាក់ព័ន្ធទាំងអស់
- ពិនិត្យ និងសម្រេចលើការស្នើសុំចូលជាសមាជិក **ប.វ.អ.** និងការស្នើសុំនានារបស់សមាជិក **ប.វ.អ.**
- ពិនិត្យ និងកែលម្អលើវិធាន និងនីតិវិធីនៃ **ប.វ.អ.** តាមការចាំបាច់
- សម្របសម្រួល និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ការតភ្ជាប់សន្ទានកម្មជាមួយប្រព័ន្ធនានា
- គ្រប់គ្រងទិន្នន័យសមាជិកភាព **ប.វ.អ.** ដោយធានាឱ្យបាននូវសុវត្ថិភាព ឯកជនភាព និងសុចរិតភាពទិន្នន័យ

- រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកម្មវិធីផ្សព្វផ្សាយនានាពាក់ព័ន្ធនឹង **ប.វ.អ.** ដើម្បីពង្រឹងសមត្ថភាព និងជំរុញការប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិក
- រៀបចំគោលការណ៍ និងវិធានការផ្នែកសន្តិសុខសាយប័រ ដើម្បីការពារទិន្នន័យអ្នកប្រើប្រាស់ និងធានាឱ្យបាននូវអនុលោមភាពតាមបទប្បញ្ញត្តិនានា
- ធ្វើជាមជ្ឈមណ្ឌលទំនាក់ទំនងសម្រាប់ **ប.វ.អ.** ក្នុងការផ្តល់ព័ត៌មានបច្ចុប្បន្នភាពរបស់ **ប.វ.អ.** និងទទួលមតិ ឬ សំណូមពរនានាពាក់ព័ន្ធនឹង **ប.វ.អ.**
- ផ្តល់ការគាំទ្រជាប្រចាំដល់សមាជិក **ប.វ.អ.** ក្នុងពេលប្រតិបត្តិការ **ប.វ.អ.**
- សហការជាមួយភាគីពាក់ព័ន្ធដែលជាក្រសួង ស្ថាប័ន ឬអង្គភាពរដ្ឋ ក្នុងការជំរុញការធ្វើបរិវត្តកម្មឌីជីថល និងការសម្រួលនីតិវិធីនានាដែលជាប្រយោជន៍សម្រាប់ធុរជន និងសាធារណជន
- អភិវឌ្ឍ នវានុវត្ត និងកែលម្អជាប្រចាំទៅលើមុខងារ និងសមត្ថភាពរបស់ **ប.វ.អ.**
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ ៥._**

**ប.វ.អ.** គឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់រដ្ឋ ដែលមានតួនាទីជាប្រព័ន្ធកណ្តាលសម្រាប់ផ្លាស់ប្តូរវិក្កយបត្រក្នុងទម្រង់ជាអេឡិចត្រូនិករវាងភាគីអ្នកលក់ ឬ អ្នកផ្តល់សេវា និងភាគីអ្នកទិញ ឬ អ្នកទទួលសេវា។ ប្រព័ន្ធនេះ ក៏មានមុខងារក្នុងការផ្តល់អត្តសញ្ញាណ និងបញ្ជាក់ទទួលស្គាល់វិក្កយបត្រអេឡិចត្រូនិកជាផ្លូវការ ដោយមិនតម្រូវឱ្យមានការបោះពុម្ពវិក្កយបត្រជាក្រដាសទៀតឡើយ។

**ប្រការ ៦._**

វិក្កយបត្រអេឡិចត្រូនិក គឺជាវិក្កយបត្រដែលបានបញ្ជូនក្នុងទម្រង់ជាអេឡិចត្រូនិកឆ្លងកាត់ការពិនិត្យ និងផ្តល់អត្តសញ្ញាណជាវិក្កយបត្រអេឡិចត្រូនិកដោយ **ប.វ.អ.**។

វិក្កយបត្រអេឡិចត្រូនិកនេះ ត្រូវបានទទួលស្គាល់ជាភស្តុតាង និងជាកំណត់ត្រាទម្រង់ឌីជីថល ដែលមានសុពលភាព និងអានុភាពគតិយុត្ត ដោយអនុលោមតាមបទប្បញ្ញត្តិគតិយុត្តជាធរមាន។

វិក្កយបត្រអេឡិចត្រូនិកនេះ នឹងត្រូវរក្សាទុកជាកំណត់ត្រាទម្រង់ឌីជីថលរយៈពេល ១០ (ដប់) ឆ្នាំ សម្រាប់ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ និងបញ្ជាក់ភាពដើមនៃវិក្កយបត្រ ក្នុងករណីផ្លូវច្បាប់ចាំបាច់តែប៉ុណ្ណោះ។

វិក្កយបត្រអេឡិចត្រូនិកនេះ អាចប្រើប្រាស់បានដោយសមាជិកនៃ **ប.វ.អ.** ចាប់ពីការចូលជាធរមាននៃប្រកាសនេះ។

**ប្រការ ៧._**

សមាជិកនៃ **ប.វ.អ.** ត្រូវបានចែកចេញជា២ (ពីរ) ប្រភេទ រួមមាន៖ សមាជិកជាអ្នកប្រើប្រាស់ និងសមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ។

សមាជិកជាអ្នកប្រើប្រាស់ សំដៅដល់ភាគីអ្នកលក់ ឬ ភាគីអ្នកផ្តល់សេវា និងភាគីអ្នកទិញ ឬ ភាគីអ្នកទទួលសេវា។ ភាគីអ្នកលក់ ឬ ភាគីអ្នកផ្តល់សេវា គឺជាអ្នកបង្កើត និងបញ្ជូនវិក្កយបត្រអេឡិចត្រូនិក។ ភាគីអ្នកទិញ ឬ ភាគីអ្នកទទួលសេវា គឺជាអ្នកទទួលវិក្កយបត្រអេឡិចត្រូនិក។

សមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ សំដៅដល់ក្រុមហ៊ុន ឬ ស្ថាប័នដែលជាអ្នកផ្គត់ផ្គង់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលត្រូវភ្ជាប់សន្ធានកម្មជាមួយ **ប.វ.អ.** ដើម្បីធ្វើអន្តរប្រតិបត្តិការជាមួយប្រព័ន្ធរបស់សមាជិកដែលជាអ្នកផ្គត់ផ្គង់ប្រព័ន្ធទាំងអស់។

វិធាន និងនីតិវិធីនៃការចូលជាសមាជិក **ប.រ.អ.** ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។ សមាជិកនៃ **ប.រ.អ.** ត្រូវគោរព និងអនុវត្តតាមវិធាន និងនីតិវិធីនេះ។

**ប្រការ ៨._**

បុគ្គលដែលមិនមែនជាសមាជិក **ប.រ.អ.** ប្រើប្រាស់ **ប.រ.អ.** ដើម្បីធ្វើសកម្មភាពណាមួយដោយពុំមានការអនុញ្ញាតពីអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ រាល់សកម្មភាពដែលផ្ទុយនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃ ព្រះរាជាណាចក្រកម្ពុជានឹងត្រូវទទួលទោសអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៩._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១០._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៨រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## នៃប្រកាសលេខ០៧៥ សហវ.ប្រក.អគព ចុះថ្ងៃទី២២ ខែ[illegible] ឆ្នាំ២០២៥

## ស្ដីពី

## ការដាក់ឱ្យដំណើរការប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា

### សទ្ទានុក្រម

**ក**

**ក្រុមហ៊ុនផ្គត់ផ្គង់ប្រព័ន្ធ** គឺជាក្រុមហ៊ុនឯកជន ដែលផ្គត់ផ្គង់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលមានមុខងារបង្កើតវិក្កយបត្រសម្រាប់ក្រុមហ៊ុនផ្គត់ផ្គង់ទំនិញ និងសេវាកម្ម ឬ ស្ថាប័នផ្សេងៗ។

**វ**

**វិក្កយបត្រ** មានពីរប្រភេទគឺ វិក្កយបត្រអាករ និងវិក្កយបត្រធម្មតា។

**វិក្កយបត្រអាករ** មាននិទ្ទេសដូចតទៅ៖

- ឈ្មោះសហគ្រាស អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកលក់ឬអ្នកផ្គត់ផ្គង់
- លេខរៀងវិក្កយបត្រតាមលំដាប់ និងកាលបរិច្ឆេទចេញវិក្កយបត្រ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទិញ ព្រមទាំងលេខអត្តសញ្ញាណកម្មសារពើពន្ធ
- សេចក្ដីបរិយាយមុខទំនិញឬសេវា បរិមាណ និងថ្លៃ
- តម្លៃសរុបនៃប្រភេទទំនិញនីមួយៗដែលមិនទាន់គិតអាករនានា
- ប្រាក់អាករនីមួយៗ (ករណីទំនិញឬសេវាត្រូវជាប់អាករពិសេស អាករសម្រាប់បំភ្លឺសាធារណៈ ឬ/និង អាករលើការស្នាក់នៅ) និងអាករលើតម្លៃបន្ថែម
- ហត្ថលេខា និងឈ្មោះរបស់អ្នកលក់និងអ្នកទិញ (ចំពោះអ្នកទិញដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងសម្រាប់វិក្កយបត្រក្រដាស)។

**វិក្កយបត្រធម្មតា** មាននិទ្ទេសដូចតទៅ៖

- ឈ្មោះសហគ្រាស អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកលក់ឬអ្នកផ្គត់ផ្គង់
- លេខរៀងវិក្កយបត្រតាមលំដាប់ និងកាលបរិច្ឆេទចេញវិក្កយបត្រ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទិញ
- សេចក្ដីបរិយាយមុខទំនិញឬសេវា បរិមាណ និងថ្លៃ
- តម្លៃរួមបញ្ចូលទាំងអាករនានានៃទំនិញនីមួយៗ
- ហត្ថលេខា និងឈ្មោះរបស់អ្នកលក់ (សម្រាប់វិក្កយបត្រក្រដាស)។

**ស**

**សន្ធានកម្ម** គឺជាច្រកចេញចូលស្តង់ដារដែលអនុញ្ញាតឱ្យទិន្នន័យអាចផ្លាស់ប្ដូរពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ ទៅប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយផ្សេងទៀត។

**អ**

**អន្តរប្រតិបត្តិការ** គឺជាសមត្ថភាពនៃប្រព័ន្ធឌីជីថល ដែលអាចធ្វើសន្ធានកម្មជាមួយគ្នាក្នុងការផ្លាស់ប្ដូរ និងការប្រើប្រាស់ទិន្នន័យ ដែលជាទូទៅកើតឡើងដោយស្វ័យប្រវត្តិតាមលក្ខខណ្ឌកំណត់។

**អ្នកលក់ ឬ អ្នកផ្តល់សេវា** គឺជាអ្នកផ្គត់ផ្គង់ទំនិញ ឬ សេវាទៅកាន់អ្នកទិញ ឬ អ្នកទទួលសេវា និងមានកាតព្វកិច្ចបង្កើត និងបញ្ជូនវិក្កយបត្រទៅកាន់អ្នកទិញ ឬ អ្នកទទួលសេវា។

**អ្នកទិញ ឬ អ្នកទទួលសេវា** គឺជាអតិថិជន ឬ អ្នកទទួលផលទំនិញ ឬ សេវាពីអ្នកលក់ ឬ អ្នកផ្តល់សេវា និងមានកាតព្វកិច្ចទទួលវិក្កយបត្រពីប្រតិបត្តិការនោះ។

# ឧបសម្ព័ន្ធទី២

## នៃប្រកាសលេខ ០៧៥ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០២៥

## ស្តីពី

## ការដាក់ឱ្យដំណើរការប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា

## វិធាន និងនីតិវិធី នៃការចូលជាសមាជិក

# វិធាន និង នីតិវិធី

## នៃការចូលជាសមាជិក
## ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា




រៀបចំដោយ

**អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល**

General Department of Digital Economy

២០២៥

# បុព្វកថា

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានផ្តល់ការទុកចិត្តពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីដឹកនាំការអភិវឌ្ឍប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា ស្របតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥។ ក្នុងនេះផងដែរ អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានប្រគល់ភារកិច្ច ក្នុងការសម្របសម្រួល និងដឹកនាំការអភិវឌ្ឍប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា និងជាប្រតិបត្តិកររបស់ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា។ អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញបេសកកម្ម ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល នៃព្រះរាជាណាចក្រកម្ពុជា ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារនិងសមធម៌សង្គមអនុលោមតាមគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល។

ដើម្បីគាំទ្រដល់ការអនុវត្តប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល បានរៀបចំ និងចងក្រងឯកសារវិធាន និង នីតិវិធីនៃការចូលជាសមាជិកនៃប្រព័ន្ធវិក្កយបត្រអេឡិច-ត្រូនិកកម្ពុជា ដើម្បីជាមូលដ្ឋានគតិយុត្ត និងផ្តល់ការណែនាំ អំពីការចុះឈ្មោះជាសមាជិកនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា។ វិធាន និង នីតិវិធីនេះ កំណត់ពីសិទ្ធិ កាតព្វកិច្ច ជំហានសំខាន់ៗ តម្រូវការ និងទំនួលខុសត្រូវ ដោយអនុលោមតាមក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការអនុវត្តការប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិក គឺជាជំហានដ៏សំខាន់មួយនៅក្នុងដំណើរនៃការឆ្ពោះទៅរកការចាប់យកឌីជីថល ការធ្វើបរិវត្តកម្មឌីជីថល និង ការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុទាំងវិស័យសាធារណៈ និងវិស័យឯកជន ស្របតាមនិន្នាការពិភពលោក និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញបរិវត្តកម្មឌីជីថលនៅកម្ពុជា។

ឯកសារនេះត្រូវបានចងក្រងឡើង សម្រាប់ជាមគ្គុទេសក៍ដល់ភាគីពាក់ព័ន្ធទាំងអស់ប្រើប្រាស់សម្រាប់ការចុះឈ្មោះចូលជាសមាជិកនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា ដើម្បីប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិកជាផ្លូវការ។

# មាតិកា


**ផ្នែកទី១៖ សេចក្តីផ្តើម** ........ ១

១.១. គោលបំណង ........ ១

១.២. វិសាលភាព ........ ១

១.៣. ការធ្វើបច្ចុប្បន្នភាពឯកសារ ........ ១

១.៤. វាក្យសព្ទបច្ចេកទេស ........ ១

**ផ្នែកទី២៖ សមាជិកភាព** ........ ៣

២.១. ប្រភេទនៃសមាជិក ........ ៣

២.២. លក្ខខណ្ឌដើម្បីក្លាយជាសមាជិក ប.វ.អ. ........ ៣

២.៣. នីតិវិធីនៃការដាក់ពាក្យស្នើសុំចូលជាសមាជិក ប.វ.អ. ........ ៥

២.៤. កាតព្វកិច្ចនៃការធ្វើតេស្ត ........ ៧

២.៥. ការបញ្ជាក់សមាជិកភាពជាផ្លូវការ ........ ៧

២.៦. ការបញ្ចប់សមាជិកភាព ........ ៧

**ផ្នែកទី៣៖ តួនាទី និងភារកិច្ច** ........ ៨

៣.១. តួនាទី និងភារកិច្ចរបស់ប្រតិបត្តិករ ប.វ.អ. ........ ៨

៣.២. តួនាទី និងភារកិច្ចរបស់សមាជិកនៃ ប.វ.អ. ........ ៩

**ផ្នែកទី៤៖ កិច្ចដំណើរការប្រព័ន្ធ** ........ ១០

៤.១. មុខងារប្រព័ន្ធ ........ ១០

៤.២. ម៉ោងប្រតិបត្តិការ ........ ១១

**ផ្នែកទី៥៖ គោលការណ៍សុវត្ថិភាព** ........ ១១

**ផ្នែកទី៦៖ ការថែទាំ និងការដោះស្រាយបញ្ហាបច្ចេកទេស** ........ ១២

**ផ្នែកទី៧៖ ការដោះស្រាយវិវាទ** ........ ១៣

**ផ្នែកទី៨៖ វិធានទូទៅ** ........ ១៣

**ឧបសម្ព័ន្ធទី១៖ ពាក្យស្នើសុំចូលជាសមាជិក ប.វ.អ.ជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ** ........ ១៥

**ឧបសម្ព័ន្ធទី២៖ ពាក្យស្នើសុំបោះបង់សមាជិកភាពពី ប.វ.អ.** ........ ១៦

**ឧបសម្ព័ន្ធទី៣ ៖ លិខិតប្រគល់សិទ្ធិ**....................................................................... ១៧
**ឧបសម្ព័ន្ធទី៤ ៖ ការធ្វើតេស្តសន្ធានកម្ម** (សម្រាប់សមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ) ........... ១៨

# ផ្នែកទី១៖ សេចក្តីផ្តើម

## ១.១. គោលបំណង

ឯកសារវិធាន និង នីតិវិធីនៃការចូលជាសមាជិកនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា (ដែលហៅកាត់ថា **ប.វ.អ.**) រៀបចំឡើងដើម្បីផ្តល់ជាគោលការណ៍ណែនាំ នីតិវិធី និងជាត្រីវិស័យសម្រាប់ចង្អុលបង្ហាញអំពីដំណើរការនៃការចុះឈ្មោះចូលជាសមាជិករបស់ **ប.វ.អ.** ជូនទៅភាគីពាក់ព័ន្ធទាំងអស់ដើម្បីយកទៅអនុវត្ត ដោយធានាឱ្យបាននូវដំណើរការនៃការចុះឈ្មោះប្រកបដោយប្រសិទ្ធភាព និងអនុលោមភាព។

## ១.២. វិសាលភាព

ឯកសារនេះមានវិសាលភាពគ្របដណ្តប់លើដំណើរការនៃការចុះឈ្មោះចូលជាសមាជិកនៃ **ប.វ.អ.** របស់កម្ពុជា ដែលរួមមាន តួនាទី ការទទួលខុសត្រូវ និងលក្ខខណ្ឌតម្រូវការរបស់អ្នកស្នើសុំចុះឈ្មោះ របៀបនៃការចុះឈ្មោះ និងដំណើរការជាជំហានៗសម្រាប់ការចុះឈ្មោះ។ ឯកសារនេះ ក៏នឹងផ្តល់នូវលក្ខខណ្ឌបច្ចេកទេសផងដែរសម្រាប់ការតភ្ជាប់សន្ទានកម្ម និងការធ្វើអន្តរប្រតិបត្តិការរវាង **ប.វ.អ.** ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានការពាក់ព័ន្ធ។

## ១.៣. ការធ្វើបច្ចុប្បន្នភាពឯកសារ

ឯកសារនេះត្រូវបានចាត់ទុកជា "ឯកសាររស់" ដែលអាចនឹងធ្វើការកែសម្រួលបន្ថែមជាយថាហេតុដើម្បីធានាបាននូវសង្គតិភាព និងការវិវត្តនៃ **ប.វ.អ.** ជាក់ស្តែង ឬផ្អែកលើការកែសម្រួលលិខិតបទដ្ឋានគតិយុត្តដែលមានការពាក់ព័ន្ធនានា។

## ១.៤. វាក្យសព្ទបច្ចេកទេស

វាក្យសព្ទបច្ចេកទេសដែលមាននៅក្នុងវិធាន និង នីតិវិធីនេះមានដូចតទៅ៖

- **ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា** (**Cambodia E-Invoicing System**) (**ប.វ.អ.**) គឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់រដ្ឋ ដែលមានតួនាទីជាប្រព័ន្ធកណ្តាលសម្រាប់ផ្លាស់ប្តូរវិក្កយបត្រក្នុងទម្រង់ជាអេឡិចត្រូនិករវាងភាគីអ្នកលក់ ឬ អ្នកផ្តល់សេវា និងភាគីអ្នកទិញ ឬ អ្នកទទួលសេវា។ ប្រព័ន្ធនេះ មានមុខងារក្នុងការផ្តល់អត្តសញ្ញាណ និងបញ្ជាក់ទទួលស្គាល់វិក្កយបត្រអេឡិចត្រូនិកជាផ្លូវការ ដោយមិនតម្រូវឱ្យមានការបោះពុម្ពវិក្កយបត្រជាក្រដាសទៀតឡើយ។ **ប.វ.អ.** មានតួនាទីជួយពិនិត្យភាពគ្រប់គ្រាន់នៃទិន្នន័យចាំបាច់របស់វិក្កយបត្រ បញ្ជាក់ភាពដើមនៃវិក្កយបត្រ ជួយពិនិត្យសុពលភាពរបស់ក្រុមហ៊ុន និងផ្តល់ការតភ្ជាប់រវាងប្រព័ន្ធចេញវិក្កយបត្រនិងប្រព័ន្ធទទួលវិក្កយបត្រ របស់ភាគីអ្នកលក់ និងភាគីអ្នកទិញ ដោយធ្វើការទំនាក់ទំនងគ្នាជាអន្តរប្រតិបត្តិការ បើទោះបីជាភាគីទាំងពីរប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងៗគ្នាក៏ដោយ។

- **វិក្កយបត្រអេឡិចត្រូនិក** គឺជាវិក្កយបត្រដែលបានបញ្ជូនក្នុងទម្រង់ជាអេឡិចត្រូនិកឆ្លងកាត់ការពិនិត្យ និងផ្ដល់អត្តសញ្ញាណជាវិក្កយបត្រអេឡិចត្រូនិកដោយ **ប.វ.អ.**។
- **ផតថលវិក្កយបត្រអេឡិចត្រូនិកកម្ពុជា** (**Cambodia E-Invoicing Portal**) ជាប្រព័ន្ធគ្រប់គ្រងវិក្កយបត្រសាមញ្ញមួយ បង្កើតឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានមុខងារបង្កើត ផ្ញើ និងទទួលវិក្កយបត្រតាម **ប.វ.អ.** សម្រាប់ផ្ដល់ជូនភាគីអ្នកលក់ ឬភាគីអ្នកផ្ដល់សេវា និងភាគីអ្នកទិញ ឬអ្នកទទួលសេវា ប្រើប្រាស់ក្នុងករណីមិនទាន់មានប្រព័ន្ធវិក្កយបត្រ ឬប្រព័ន្ធគណនេយ្យផ្ទាល់ខ្លួនដើម្បីប្រើប្រាស់ ឬករណីមិនទាន់បានភ្ជាប់ប្រព័ន្ធរបស់ខ្លួនជាមួយ **ប.វ.អ.** នៅឡើយ។
- **សមាជិកជាអ្នកប្រើប្រាស់** (**Member as End-User**) ជាសមាជិកនៃ **ប.វ.អ.** ដែលសំដៅដល់ភាគីអ្នកលក់ ឬ ភាគីអ្នកផ្ដល់សេវា និងភាគីអ្នកទិញ ឬ ភាគីអ្នកទទួលសេវា ដែលភាគីអ្នកលក់ ឬ ភាគីអ្នកផ្ដល់សេវាគឺជាអ្នកបង្កើត និងបញ្ជូនវិក្កយបត្រអេឡិចត្រូនិក រីឯភាគីអ្នកទិញ ឬ ភាគីអ្នកទទួលសេវា គឺជាអ្នកទទួលវិក្កយបត្រអេឡិចត្រូនិក។
- **សមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ** (**Member as Service Provider**) ជាសមាជិកនៃ **ប.វ.អ.** ដែលជាក្រុមហ៊ុនផ្គត់ផ្គង់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងការចេញវិក្កយបត្រ ឬការទទួលវិក្កយបត្រ ជូនទៅ "សមាជិកជាអ្នកប្រើប្រាស់"។
- **សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ** (**Application Programming Interface – API**) សំដៅដល់ច្រកចេញចូលស្តង់ដាដែលអនុញ្ញាតឱ្យទិន្នន័យអាចផ្លាស់ប្តូរពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ ទៅប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយផ្សេងទៀត។
- **ថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា** (**Cambodia Digital Key - CamDigiKey**) សំដៅដល់ប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល (**Electronic Know Your Customer** ឬ **e-KYC**) ដែលប្រតិបត្តិដោយប្រតិបត្តិករនៃថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (**ថ.ផ.ទ.**)។ ថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា មិនមែនជាអត្តសញ្ញាណឌីជីថលបុគ្គលទេ។
- **លេខអត្តសញ្ញាណកម្មសារពើពន្ធ** (**Tax Identification Number – TIN**) សំដៅដល់លេខសម្គាល់អ្នកជាប់ពន្ធនៅពេលចុះបញ្ជីដំបូងនៅរដ្ឋបាលសារពើពន្ធ។
- **កូដនីយកម្ម** (**Encryption**) សំដៅដល់ការបំប្លែងទិន្នន័យ ឬព័ត៌មានទៅជាកូដពិសេសណាមួយដែលគេមិនអាចយល់ ឬមិនអាចយកទៅប្រើប្រាស់បាន។
- **ថ្នាល** CamDL ពាក្យពេញថា Cambodia Distributed Ledger គឺជាថ្នាលឌីជីថលគ្រឹះដែលបានប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន ក្នុងគោលបំណងគាំទ្រដល់ការធ្វើពិសោធ អភិវឌ្ឍ ឬបង្កើតនូវកម្មវិធីបច្ចេកវិទ្យាព័ត៌មាននានា ដើម្បីដោះស្រាយបញ្ហាក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួន។

- **ប្លុកឆេន (Blockchain)** សំដៅដល់បច្ចេកវិទ្យាមួយដែលប្រើប្រាស់ក្នុងការអនុញ្ញាតឱ្យកត់ត្រា រក្សាទុក និងតាមដានប្រតិបត្តិការ និងទិន្នន័យប្រកបដោយសុក្រឹត្យភាព។

# ផ្នែកទី២៖ សមាជិកភាព

## ២.១. ប្រភេទនៃសមាជិក

សមាជិកនៃ **ប.ឯ.អ.** ត្រូវបានបែងចែកជា២ប្រភេទ គឺ៖ សមាជិកជាអ្នកប្រើប្រាស់ (End-User) និង សមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ (Service Provider)។

### ក.សមាជិកជាអ្នកប្រើប្រាស់ (End-User) ត្រូវបានបែងចែកជា២ក្រុម៖

- **សមាជិកក្រុមទី១** គឺជាស្ថាប័ន ឬអង្គភាពរដ្ឋ ដែលអាចជាអង្គភាពថវិកានៃក្រសួង-ស្ថាប័នរដ្ឋ អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ អង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត និងរដ្ឋបាលថ្នាក់ក្រោមជាតិជាដើម ដែលត្រូវក្លាយជាសមាជិកនៃ **ប.ឯ.អ.** ដោយស្វ័យប្រវត្តិ និងជាទូទៅគឺជាភាគីអ្នកទិញដែលអនុវត្តមុខងារទទួលវិក្កយបត្រ។

- **សមាជិកក្រុមទី២** គឺជាក្រុមហ៊ុន សហគ្រាសឯកជន អង្គការ សមាគមន៍ ស្ថាប័នឯកជនផ្សេងទៀត និងស្ថាប័នក្រៅរដ្ឋាភិបាលជាដើម ដែលបានចុះបញ្ជីត្រឹមត្រូវស្របច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

### ខ.សមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ (Service Provider)៖ 

សំដៅលើក្រុមហ៊ុនទាំងឡាយដែលផ្តល់សេវាកម្មផ្គត់ផ្គង់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលពាក់ព័ន្ធនឹងការចេញ ឬ ទទួលវិក្កយបត្រជូនក្រុមហ៊ុន ឬ អតិថិជនរបស់ខ្លួន ដែលជាសមាជិកនៃ **ប.ឯ.អ.** ក្នុងប្រភេទជាអ្នកប្រើប្រាស់ ដើម្បីធ្វើប្រតិបត្តិការវិក្កយបត្រអេឡិចត្រូនិក។

## ២.២. លក្ខខណ្ឌដើម្បីក្លាយជាសមាជិក ប.ឯ.អ.

### ក. សមាជិកជាអ្នកប្រើប្រាស់ ត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម៖

#### *ក.១.សមាជិកក្រុមទី១*

- មិនតម្រូវឱ្យដាក់ពាក្យស្នើសុំចូលជាសមាជិកនោះទេ គឺនឹងក្លាយជាសមាជិកដោយស្វ័យប្រវត្តិតាមការជូនដំណឹងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងអភិក្រមអនុវត្តជាជំហានៗ
- មិនអាចបោះបង់ភាពជា**សមាជិក**បានឡើយ លើកលែងតែក្នុងករណីសមាជិកនោះត្រូវបានរំលាយចោល ឬធ្វើសមាហរណកម្មផ្លាស់ប្តូរទៅជាអង្គភាពផ្សេង ស្របទៅតាមច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន ហើយភាពជាសមាជិកនោះក៏នឹងត្រូវផ្អាកដោយស្វ័យប្រវត្តិផងដែរ

- ត្រូវបញ្ជូនឈ្មោះអ្នកតំណាងរបស់អង្គភាព ឬស្ថាប័ន ជាលិខិតផ្លូវការទៅកាន់ប្រតិបត្តិករ **ប.ទ.អ.** ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណអ្នកតំណាងនោះ និងតារាងបញ្ជីឈ្មោះ និងព័ត៌មានអ្នកតំណាង
- អ្នកតំណាងរបស់អង្គភាព ឬស្ថាប័នត្រូវមានគណនី CamDigiKey ក្នុងការចូលប្រើប្រាស់ផតថលវិក្កយបត្រអេឡិចត្រូនិកកម្ពុជា
- ផ្តល់ការអនុញ្ញាតដល់អ្នកតំណាងក្នុងការចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ឬកិច្ចប្រជុំនានា តាមការអញ្ជើញរបស់ប្រតិបត្តិករ **ប.ទ.អ.**
- ត្រូវទទួលតែវិក្កយបត្រអេឡិចត្រូនិកពីក្រុមហ៊ុនផ្គត់ផ្គង់របស់ខ្លួន អនុលោមតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងក្របខណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- គ្រប់ព័ត៌មាន ឬទិន្នន័យដែលធ្វើប្រតិបត្តិការតាម **ប.ទ.អ.** គឺជាទំនួលខុសត្រូវរបស់អង្គភាពសាមីផ្ទាល់
- ត្រូវសហការ និងចូលរួមសម្របសម្រួលជាមួយប្រតិបត្តិករ **ប.ទ.អ.** ក្នុងការផ្តល់នូវមតិយោបល់ និងបញ្ហាប្រឈមនានា ចំពោះបទពិសោធន៍នៃការប្រើប្រាស់ **ប.ទ.អ.** តាមការស្នើសុំស្របតាមតម្រូវការចាំបាច់របស់ប្រតិបត្តិករ **ប.ទ.អ.**។

### *ក.២.សមាជិកក្រុមទី២*

- ត្រូវជានាថាស្ថាប័នរបស់ខ្លួន បានចុះបញ្ជីស្របច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជីពន្ធដាររួចរាល់
- ត្រូវចុះឈ្មោះស្នើសុំចូលជាសមាជិក **ប.ទ.អ.** តាមរយៈផតថលវិក្កយបត្រអេឡិចត្រូនិកកម្ពុជា ដោយខ្លួនឯង ឬស្នើសុំជំនួយគាំទ្រពីប្រតិបត្តិករ **ប.ទ.អ.**
- ត្រូវប្រើប្រាស់គណនី CamDigiKey ដើម្បីចូលផតថលវិក្កយបត្រអេឡិចត្រូនិកកម្ពុជា
- ក្នុងករណីអ្នកចុះឈ្មោះជាអ្នកតំណាងនៃក្រុមហ៊ុន សហគ្រាស ឬស្ថាប័នឯកជនផ្សេងទៀត គឺតម្រូវឱ្យមានលិខិតប្រគល់សិទ្ធិដូចមានគំរូភ្ជាប់ក្នុង **ឧបសម្ព័ន្ធទី៣**
- ត្រូវធានាអះអាងថារាល់ព័ត៌មានដែលបានផ្តល់ជូនប្រតិបត្តិករ **ប.ទ.អ.** សុទ្ធតែជាព័ត៌មានត្រឹមត្រូវ និងពិតប្រាកដ
- គ្រប់ព័ត៌មាន ឬទិន្នន័យនៅក្នុងប្រតិបត្តិការវិក្កយបត្រទាំងអស់ ជាទំនួលខុសត្រូវរបស់អង្គភាពសាមីផ្ទាល់
- ត្រូវសហការ និងចូលរួមសម្របសម្រួលផ្តល់ព័ត៌មានផ្សេងៗជាមួយប្រតិបត្តិករ **ប.ទ.អ.**
- ត្រូវទទួលស្គាល់ថារាល់ប្រតិបត្តិការវិក្កយបត្ររបស់ខ្លួនក្នុង **ប.ទ.អ.** ពិតជាបានឆ្លងកាត់ការត្រួតពិនិត្យត្រឹមត្រូវ

- គ្រប់ព័ត៌មាន ឬទិន្នន័យដែលធ្វើប្រតិបត្តិការតាម **ប.វ.អ.** គឺជាទំនួលខុសត្រូវរបស់អង្គភាពសាមីផ្ទាល់
- ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានស្ថាប័នរបស់ខ្លួនឱ្យបានទាន់ពេល ក្នុងករណីមានការផ្លាស់ប្តូរ
- ត្រូវគោរពតាមលក្ខខណ្ឌផ្សេងៗទៀត ទៅតាមការជូនដំណឹងឬសេចក្តីណែនាំពីប្រតិបត្តិករ **ប.វ.អ.** ឬពីស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធនានា
- ករណីក្រុមហ៊ុន សហគ្រាស ឬស្ថាប័នឯកជនផ្សេងទៀត មានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្ទាល់ខ្លួន និងត្រូវការតភ្ជាប់ផ្ទាល់ជាមួយ **ប.វ.អ.** ត្រូវគោរពលក្ខខណ្ឌបច្ចេកទេសនានា ដូចករណីការភ្ជាប់ប្រព័ន្ធរបស់សមាជិកជាផ្គត់ផ្គង់ប្រព័ន្ធផងដែរ។

### ខ. សមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ ត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវធានាថាក្រុមហ៊ុនរបស់ខ្លួន បានចុះបញ្ជីស្របច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួមទាំងបានចុះបញ្ជីពន្ធដាររួចរាល់
- ត្រូវដាក់ពាក្យស្នើសុំភ្ជាប់សន្ទានកម្មរវាងប្រព័ន្ធរបស់ខ្លួនជាមួយនឹង **ប.វ.អ.** ជាមុនដោយត្រូវបំពេញទម្រង់បែបបទដូចមានភ្ជាប់ក្នុង **ឧបសម្ព័ន្ធទី១** និងគោរពតាមលក្ខខណ្ឌបច្ចេកទេសដែលបានកំណត់ដោយ **ប.វ.អ.**
- ធានាថារាល់ព័ត៌មានដែលបានផ្តល់ជូនប្រតិបត្តិករ **ប.វ.អ.** សុទ្ធតែជាព័ត៌មានត្រឹមត្រូវ និងពិតប្រាកដ
- ធានាថាជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលខ្លួនផ្គត់ផ្គង់ មានមុខងារពាក់ព័ន្ធនឹងប្រតិបត្តិការវិក្កយបត្រ ដូចជាប្រព័ន្ធចេញវិក្កយបត្រ ប្រព័ន្ធគណនេយ្យ ប្រព័ន្ធ ERP (Enterprise Resource Planning) ជាដើម
- ធានាថាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួនមានមុខងារបង្កើត ផ្ញើ ទទួល និងកំណត់សម្គាល់ស្ថានភាពវិក្កយបត្រ ("រង់ចាំ" "បានទទួល" "បដិសេធ")
- ធានាថាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួនទ្រទ្រង់វិក្កយបត្រដែលមានទម្រង់ជា XML
- ធានាថាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួនមានសុវត្ថិភាព និងគុណភាព
- គោរពតាមលក្ខខណ្ឌផ្សេងទៀត ដែលនឹងមានចែងនៅក្នុងអនុស្សារណៈនៃការយោគយល់ ឬទៅតាមសេចក្តីណែនាំរបស់ប្រតិបត្តិករ **ប.វ.អ.** ។

## ២.៣. នីតិវិធីនៃការដាក់ពាក្យស្នើសុំចូលជាសមាជិក ប.វ.អ.

### ក. សមាជិកជាអ្នកប្រើប្រាស់ (សម្រាប់តែសមាជិកក្រុមទី២)

- ចូលទៅកាន់គេហទំព័ររបស់ **ប.ទ.អ.** រួចបន្តការចុះឈ្មោះនៅក្នុង **ផតថលវិក្កយបត្រអេឡិចត្រូនិកកម្ពុជា** ដោយប្រើប្រាស់កម្មវិធី CamDigiKey នៅក្នុងទូរសព្ទដៃ
- បំពេញព័ត៌មានឱ្យបានត្រឹមត្រូវ និងភ្ជាប់ជាមួយលិខិតប្រគល់សិទ្ធិ (ករណីចុះឈ្មោះដោយអ្នកតំណាង) ផ្អែកតាមទម្រង់ដែលផ្តល់ជូននៅក្នុងផតថល
- ប្រតិបត្តិករ **ប.ទ.អ.** នឹងពិនិត្យទៅលើសំណើសុំចូលជាសមាជិក និងគុណវុឌ្ឍិរបស់ក្រុមហ៊ុនសហគ្រាស ឬស្ថាប័នឯកជនផ្សេងទៀត ដែលបានដាក់ការស្នើសុំចូលជាសមាជិក ក្នុងរយៈពេលយ៉ាងយូរ ៨ម៉ោង (ប្រាំបីម៉ោង) នៃម៉ោងធ្វើការ និងជូនដំណឹងអំពីលទ្ធផលនៃការស្នើសុំតាមរយៈអ៊ីមែល ឬទូរសព្ទដៃ
- បន្ទាប់ពីក្លាយជាសមាជិកជាអ្នកប្រើប្រាស់, សមាជិកអាចប្រើប្រាស់**ផតថលវិក្កយបត្រអេឡិចត្រូនិកកម្ពុជា** ក្នុងការគ្រប់គ្រងលើជម្រើសនៃការប្រើប្រាស់ប្រព័ន្ធវិក្កយបត្រណាមួយសម្រាប់ដំណើរការវិក្កយបត្រអេឡិចត្រូនិករបស់ស្ថាប័នខ្លួន ក្នុងនោះ **ផតថលវិក្កយបត្រអេឡិចត្រូនិកកម្ពុជា** គឺជាជម្រើសដែលជ្រើសរើសស្រាប់ (By Default) និងអាចផ្លាស់ប្តូរដោយជ្រើសរើសប្រព័ន្ធណាមួយរបស់សមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ ដែលសមាជិកកំពុងប្រើប្រាស់
- ក្នុងករណីសមាជិក **ប.ទ.អ.** មានប្រើប្រាស់ប្រព័ន្ធវិក្កយបត្រដែលរៀបចំដោយក្រុមការងារផ្ទាល់ខ្លួន, សមាជិកអាចទំនាក់ទំនងទៅកាន់ប្រតិបត្តិករ ដើម្បីពិនិត្យលទ្ធភាពភ្ជាប់សន្ទានកម្មប្រព័ន្ធនោះជាមួយ **ប.ទ.អ.** ដោយគោរពលក្ខខណ្ឌបច្ចេកទេសនានា ដូចករណីភ្ជាប់សន្ទានកម្មប្រព័ន្ធរបស់សមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធផងដែរ។

### ខ. សមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ

- សូមចូលទៅកាន់គេហទំព័ររបស់ **ប.ទ.អ.** រួចបំពេញពាក្យស្នើសុំជាបេក្ខភាពចូលជាសមាជិកអ្នកផ្គត់ផ្គង់ប្រព័ន្ធ និងរង់ចាំការទំនាក់ទំនងពីប្រតិបត្តិករ **ប.ទ.អ.**
- ប្រតិបត្តិករ **ប.ទ.អ.** នឹងពិនិត្យទៅលើសំណើដែលបានស្នើមក រួមទាំងពិនិត្យគុណវុឌ្ឍិរបស់ក្រុមហ៊ុនក្នុងរយៈពេលយ៉ាងយូរ ៨ម៉ោង (ប្រាំបីម៉ោង) នៃម៉ោងធ្វើការ រួចនឹងផ្ញើត្រឡប់ទៅវិញនូវពាក្យស្នើសុំចូលជាសមាជិករបស់ **ប.ទ.អ.** ក្នុងប្រភេទជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ ដូចមានភ្ជាប់ក្នុង **ឧបសម្ព័ន្ធទី១** និងធ្វើការទំនាក់ទំនងការងារជាបន្តបន្ទាប់តាមរយៈ អ៊ីមែល ឬអាចអញ្ជើញជួបប្រជុំពិភាក្សាការងារនានាតាមការចាំបាច់
- មុននឹងចាប់ផ្តើមការងារបច្ចេកទេសជាមួយគ្នា ក្រុមហ៊ុនត្រូវចុះកិច្ចព្រមព្រៀងរក្សាការសម្ងាត់ (Non-Disclosure Agreement - NDA) ជាមួយប្រតិបត្តិករ **ប.ទ.អ.**
- បន្ទាប់ពីទទួលបានជោគជ័យ ក្នុងការងារបច្ចេកទេសតភ្ជាប់សន្ទានកម្មរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រុមហ៊ុន ជាមួយនឹង **ប.ទ.អ.** ភាគីទាំងពីរនឹងចុះហត្ថលេខាលើអនុស្សរណៈនៃ

ការយោគយល់គ្នា (Memorandum of Understanding - MOU) ដើម្បីក្លាយជាសមាជិកអ្នកផ្គត់ផ្គង់ប្រព័ន្ធផ្លូវការរបស់ **ប.វ.អ.**។

## ២.៤. កាតព្វកិច្ចនៃការធ្វើតេស្ត

ចំណុចនេះ អនុវត្តចំពោះតែសមាសភាពស្នើសុំចូលជាសមាជិកអ្នកផ្គត់ផ្គង់ប្រព័ន្ធប៉ុណ្ណោះ។

ក. ប្រតិបត្តិករ **ប.វ.អ.** អាចកំណត់អំពីវិធី និងកាលបរិច្ឆេទនៃការធ្វើតេស្តសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (API) តាមលក្ខណៈស្តង់ដារដើម្បីធានានូវប្រសិទ្ធភាពនៃដំណើរការប្រតិបត្តិការរវាងប្រព័ន្ធរបស់សមាជិក និង **ប.វ.អ.**។ សមាសភាពដែលស្នើសមាជិកភាពត្រូវអនុវត្តការធ្វើតេស្តសន្ទានកម្មប្រព័ន្ធឱ្យស្របតាមតម្រូវការមុខងារសុវត្ថិភាព និងមុខងារចាំបាច់ផ្សេងៗទៀតនៃ **ប.វ.អ.** ដែលកំណត់ដោយប្រតិបត្តិករ **ប.វ.អ.**។

ខ. ប្រតិបត្តិករ **ប.វ.អ.** និងសមាសភាពស្នើសុំជាសមាជិក ត្រូវរៀបចំផែនការ និងអនុវត្តតាមផែនការនោះក្នុងការធ្វើតេស្តរួមគ្នា ។

គ. សមាសភាពស្នើសុំជាសមាជិក ត្រូវធានាថាក្រុមការងារដែលចាត់តាំងដើម្បីចូលរួមធ្វើតេស្តលើការធ្វើសន្ទានកម្មប្រព័ន្ធ មានចំណេះដឹង និងគុណវុឌ្ឍិគ្រប់គ្រាន់សម្រាប់ការងារធ្វើតេស្តនេះ។

ឃ. បន្ទាប់ពីធ្វើតេស្តបានជោគជ័យ សមាសភាពស្នើសុំជាសមាជិក និងប្រតិបត្តិករ **ប.វ.អ.** ត្រូវចុះហត្ថលេខាទទួលស្គាល់លើឯកសារលទ្ធផលនៃការធ្វើតេស្ត ដូចមានគំរូភ្ជាប់ក្នុង **ឧបសម្ព័ន្ធទី៤**។

## ២.៥. ការបញ្ជាក់សមាជិកភាពជាផ្លូវការ

សមាសភាពដែលបំពេញគ្រប់លក្ខខណ្ឌសម្រាប់ការសុំចូលជាសមាជិក **ប.វ.អ.** នឹងទទួលបានការអនុម័តបញ្ជាក់ការទទួលស្គាល់ជាសមាជិកផ្លូវការរបស់ **ប.វ.អ.** តាមរយៈការជូនដំណឹងជាផ្លូវការពីប្រតិបត្តិករ **ប.វ.អ.**។ ក្រោយពីទទួលបាននូវការជូនដំណឹងនេះ សមាជិក **ប.វ.អ.** អាចចាប់ផ្តើមធ្វើប្រតិបត្តិការជាមួយ **ប.វ.អ.** ជាផ្លូវការ។

## ២.៦. ការបញ្ចប់សមាជិកភាព

ការបញ្ចប់សមាជិកភាពពី **ប.វ.អ.** អាចកើតឡើងក្នុង ២ (ពីរ) រូបភាពគឺ ទី១) ការបញ្ចប់សមាជិកភាព តាមការស្នើសុំរបស់សមាជិក **ប.វ.អ.** និង ទី២) ការបញ្ចប់សមាជិកភាពតាមសេចក្តីសម្រេចរបស់ប្រតិបត្តិករ **ប.វ.អ.**។

### ក. ការបញ្ចប់សមាជិកភាពតាមការស្នើសុំរបស់សមាជិក ប.វ.អ.

សមាជិកដែលមានបំណងចង់បញ្ចប់ ឬបោះបង់សមាជិកភាពពី **ប.វ.អ.** ត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរ ដែលមានទម្រង់ដូចមានភ្ជាប់ក្នុង**ឧបសម្ព័ន្ធទី២** ទៅកាន់ប្រតិបត្តិករ **ប.វ.អ.** ដោយបញ្ជាក់ពីហេតុផលច្បាស់លាស់ ព្រមទាំងភ្ជាប់មកជាមួយនូវព័ត៌មានពាក់ព័ន្ធ ដើម្បីគាំទ្រដល់ការស្នើបញ្ចប់

សមាជិកភាពរបស់ខ្លួន។ សមាជិកភាព **ប.វ.អ.** នឹងត្រូវបញ្ចប់ជាស្ថាពរ និងមានប្រសិទ្ធភាពគិតចាប់ពីថ្ងៃដែលទទួលបានការជូនដំណឹងជាផ្លូវការពីប្រតិបត្តិករ **ប.វ.អ.**។

### ខ. ការបញ្ចប់សមាជិកភាពតាមសេចក្តីសម្រេចរបស់ប្រតិបត្តិករ ប.វ.អ.

ប្រតិបត្តិករ **ប.វ.អ.** មានសិទ្ធិក្នុងការព្យួរ ឬបញ្ឈប់សមាជិកភាពនៃ **ប.វ.អ.** ក្នុងករណីរកឃើញថា សមាជិកនោះបានប្រព្រឹត្តសកម្មភាពមិនប្រក្រតីណាមួយ ដែលខុសពីគោលការណ៍ ឬលក្ខខណ្ឌជាសមាជិកភាព។ សមាជិកភាព **ប.វ.អ.** ត្រូវបានបញ្ចប់ជាស្ថាពរ និងមានប្រសិទ្ធភាពភ្លាមៗបន្ទាប់ទទួលបានការសម្រេចបញ្ចប់ជាសមាជិកភាពពីប្រតិបត្តិករ **ប.វ.អ.**។ សកម្មភាពមិនប្រក្រតីនានាដែលជាកម្មវត្ថុនៃការសម្រេចបញ្ចប់សមាជិកភាពមានដូចជា៖

- ការបំពានយ៉ាងធ្ងន់ធ្ងរលើលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ការបំពាន ឬប្រព្រឹត្តខុសឆ្គងផ្ទុយពីលក្ខខណ្ឌដែលមានចែងក្នុងវិធាន និង នីតិវិធីនេះ
- ការប្រព្រឹត្តបទល្មើសបំពានទៅលើសមាជិកដទៃ ឬមិនបំពេញកាតព្វកិច្ចរបស់ខ្លួន និងមិនបានដោះស្រាយបញ្ហានេះក្នុងរយៈពេលសមរម្យណាមួយដូចបានស្នើសុំដោយភាគីម្ខាងទៀត
- ការមិនមានសកម្មភាពក្នុងការប្រើប្រាស់ប្រព័ន្ធក្នុងរយៈពេល ១២ខែ ចុងក្រោយជាប់ៗគ្នា
- ការប្រកាសបិទអាជីវកម្ម។

## ផ្នែកទី៣៖ តួនាទី និងភារកិច្ច

### ៣.១. តួនាទី និងភារកិច្ចរបស់ប្រតិបត្តិករ ប.វ.អ.

ប្រតិបត្តិករ **ប.វ.អ.** មានតួនាទី និងភារកិច្ចដូចតទៅ៖

- គ្រប់គ្រង ប្រតិបត្តិ និងតាមដានដំណើរការ **ប.វ.អ.** ជាប្រចាំ
- សម្របសម្រួល និងផ្តល់ព័ត៌មានអំពីការចុះឈ្មោះចូលជាសមាជិកនៃ **ប.វ.អ.** ជូនភាគីដែលពាក់ព័ន្ធទាំងអស់
- ពិនិត្យ និងសម្រេចលើការស្នើសុំចូលជាសមាជិក **ប.វ.អ.** និងការស្នើសុំនានារបស់សមាជិក **ប.វ.អ.**
- ពិនិត្យ និងកែលម្អលើវិធាន និង នីតិវិធីនៃ **ប.វ.អ.** តាមការចាំបាច់
- សម្របសម្រួល និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ការតភ្ជាប់សន្ទានកម្មជាមួយប្រព័ន្ធនានា
- គ្រប់គ្រងទិន្នន័យសមាជិកភាព **ប.វ.អ.** ដោយធានាឱ្យបាននូវសុវត្ថិភាព ឯកជនភាព និងសុចរិតភាពទិន្នន័យ

- រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកម្មវិធីផ្សព្វផ្សាយនានាពាក់ព័ន្ធនឹង **ប.វ.អ.** ដើម្បីពង្រឹងសមត្ថភាព និងជំរុញការប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិក
- រៀបចំគោលការណ៍ និងវិធានការផ្នែកសន្តិសុខសាយប័រ ដើម្បីការពារទិន្នន័យអ្នកប្រើប្រាស់ និងធានាឱ្យបាននូវអនុលោមភាពតាមបទប្បញ្ញត្តិនានា
- ធ្វើជាមជ្ឈមណ្ឌលទំនាក់ទំនងសម្រាប់ **ប.វ.អ.** ក្នុងការផ្តល់ព័ត៌មានបច្ចុប្បន្នភាពរបស់ **ប.វ.អ** និងទទួលមតិ ឬ សំណូមពរនានាពាក់ព័ន្ធនឹង **ប.វ.អ.**
- ផ្តល់ការគាំទ្រជាប្រចាំដល់សមាជិក **ប.វ.អ.** ក្នុងពេលប្រតិបត្តិការ **ប.វ.អ.**
- សហការជាមួយភាគីពាក់ព័ន្ធដែលជាក្រសួង-ស្ថាប័ន ឬ អង្គភាពរដ្ឋ ក្នុងការជំរុញការធ្វើបរិវត្ត-កម្មឌីជីថល និងការសម្រួលនីតិវិធីនានាដែលជាប្រយោជន៍សម្រាប់ធុរជន និងសាធារណជន
- អភិវឌ្ឍ នវានុវត្ត និងកែលម្អជាប្រចាំទៅលើមុខងារ និងសមត្ថភាពរបស់ **ប.វ.អ.**
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ៣.២. តួនាទី និងភារកិច្ចរបស់សមាជិកនៃ ប.វ.អ.

សមាជិកនៃ **ប.វ.អ.** មានតួនាទី និងភារកិច្ចដូចតទៅ៖

### ក.សមាជិកជាអ្នកប្រើប្រាស់

#### *ក.១.សមាជិកជាស្ថាប័ន ឬ អង្គភាពរដ្ឋ*

- ទទួលយកសមាជិកភាពដោយស្វ័យប្រវត្តិតាមការជូនដំណឹងពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចូលរួមប្រើប្រាស់ **ប.វ.អ.** សម្រាប់ប្រតិបត្តិការវិក្កយបត្រ
- ទទួលយកតែវិក្កយបត្រអេឡិចត្រូនិកដែលឆ្លងកាត់តាម **ប.វ.អ.** ពីក្រុមហ៊ុន/អ្នកផ្គត់ផ្គង់
- ផ្តល់នូវព័ត៌មាន ឬទិន្នន័យត្រឹមត្រូវសម្រាប់ការធ្វើប្រតិបត្តិការនានាតាម **ប.វ.អ.**
- ពិនិត្យមើលព័ត៌មាននៅក្នុងវិក្កយបត្រដែលទទួលបានពីក្រុមហ៊ុន/អ្នកផ្គត់ផ្គង់ឱ្យបានហ្មត់ចត់
- ជួយផ្សព្វផ្សាយ និងផ្តល់ដំណឹងទៅក្រុមហ៊ុន/អ្នកផ្គត់ផ្គង់របស់ខ្លួន ក្នុងការចូលជាសមាជិកនៃ **ប.វ.អ.**
- ផ្តល់សមាសភាពតំណាងស្ថាប័ន ឬ អង្គភាពរបស់ខ្លួន ដើម្បីចូលរួមវគ្គបណ្តុះបណ្តាល ធ្វើការទំនាក់ទំនងជាមួយប្រតិបត្តិការ **ប.វ.អ.** និងគាំទ្រការអនុវត្តប្រព័ន្ធក្នុងស្ថាប័ន ឬ អង្គភាពខ្លួន
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពព័ត៌មានជាសមាជិកភាពរបស់ខ្លួនក្នុងករណីមានការកែប្រែ
- លើកបញ្ហាប្រឈម ឬសំណូមពរ និងផ្តល់ការសហការក្នុងកំឡុងពេលអនុវត្ត **ប.វ.អ.**។

#### *ក.២.សមាជិកមិនមែនជាស្ថាប័ន ឬ អង្គភាពរដ្ឋ*

- ចូលរួមប្រើប្រាស់ **ប.វ.អ.** ឱ្យបានជាអតិបរមាសម្រាប់ការធ្វើប្រតិបត្តិការវិក្កយបត្រអេឡិចត្រូនិក

- បង្កើត បញ្ជូន ទទួល និងប្រើប្រាស់វិក្កយបត្រតាម **ប.វ.អ.** ដោយគោរពតាម វិធាន និងនីតិវិធីដូចបានចែងក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬលក្ខខណ្ឌ ឬ គោលការណ៍ណែនាំផ្សេងៗ ដែលបានចែងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬដោយប្រតិបត្តិករ **ប.វ.អ.**
- ពិនិត្យ បញ្ចូល ឬកត់ត្រាទិន្នន័យវិក្កយបត្រឱ្យបានត្រឹមត្រូវមុននឹងបញ្ជូនឆ្លងកាត់តាម **ប.វ.អ.**
- ក្នុងករណីមានប្រព័ន្ធប្រើប្រាស់ស្រាប់ដែលផ្គត់ផ្គង់ដោយក្រុមហ៊ុនផ្គត់ផ្គង់ប្រព័ន្ធណាមួយ ត្រូវធ្វើការសហការជាមួយក្រុមហ៊ុនផ្គត់ផ្គង់ប្រព័ន្ធនោះ ដើម្បីភ្ជាប់សន្ទានកម្មជាមួយ **ប.វ.អ.**
- ក្នុងករណីមានប្រព័ន្ធប្រើប្រាស់ស្រាប់ដែលបង្កើតដោយក្រុមហ៊ុនរបស់ខ្លួនផ្ទាល់ ត្រូវអនុវត្តនូវតួនាទី និងភារកិច្ចផ្នែកបច្ចេកទេសដូចសមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធដែរ
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពព័ត៌មានជាសមាជិកភាពរបស់ខ្លួនក្នុងករណីមានការកែប្រែ
- ចូលរួមវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលានានាតាមការអញ្ជើញរបស់ប្រតិបត្តិករ **ប.វ.អ.**
- លើកបញ្ហាប្រឈម ឬសំណូមពរ និងផ្តល់ការសហការក្នុងកំឡុងពេលអនុវត្ត **ប.វ.អ.**។

### ខ.សមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ

- ផ្តល់សេវា និងដោះស្រាយបញ្ហាឱ្យបានទាន់ពេលវេលាជូនអតិថិជនរបស់ខ្លួន ដែលជាសមាជិកជាអ្នកប្រើប្រាស់របស់ **ប.វ.អ.**
- ធ្វើបច្ចុប្បន្នកម្មលើប្រព័ន្ធរបស់ខ្លួនឱ្យស្របតាមបច្ចុប្បន្នភាពរបស់ **ប.វ.អ.** និងរ៉ាប់រងបន្ទុកចំណាយពាក់ព័ន្ធបច្ចុប្បន្នកម្មនេះ
- សហការជាមួយប្រតិបត្តិករ **ប.វ.អ.** ក្នុងការរៀបចំឱ្យមានការត្រួតពិនិត្យ និងវាយតម្លៃលើការប្រើប្រាស់ និងសន្តិសុខបច្ចេកវិទ្យាព័ត៌មានរបស់ **ប.វ.អ.** ស្របតាមតម្រូវការចាំបាច់
- ត្រូវមានមធ្យោបាយគ្រប់គ្រាន់សម្រាប់ចម្លង ឬរក្សាទុកទិន្នន័យ និងមានផែនការច្បាស់លាស់ត្រៀមក្នុងការសង្គ្រោះទិន្នន័យក្នុងពេលមានបញ្ហា
- ផ្តល់កិច្ចសហការផ្សេងៗតាមការស្នើសុំរបស់ប្រតិបត្តិករ **ប.វ.អ.** ក្នុងគោលបំណងធានាប្រសិទ្ធភាព និងនិរន្តរភាពនៃប្រតិបត្តិការ
- ក្នុងករណីមានបញ្ហាដែលនាំឱ្យមានការខាតបង់ដល់ **ប.វ.អ.** និង/ឬ សមាជិក **ប.វ.អ.** ត្រូវទទួលខុសត្រូវចំពោះការខាតបង់ទាំងនោះ។

## ផ្នែកទី៤៖ កិច្ចដំណើរការប្រព័ន្ធ

### ៤.១. មុខងារប្រព័ន្ធ

#### ក. មុខងាររបស់ ប.វ.អ. មានដូចខាងក្រោម៖

- ពិនិត្យភាពគ្រប់គ្រាន់នៃទិន្នន័យចាំបាច់ ដែលមានកំណត់នៅក្នុងប្រកាសស្ដីពីវិធាននៃការប្រើប្រាស់វិក្កយបត្រចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ភ្ជាប់ការពិនិត្យសុពលភាព និងភាពស្របច្បាប់របស់ក្រុមហ៊ុន ដោយផ្អែកតាមយន្តការនៃថ្នាលបញ្ជាក់អត្តសញ្ញាណសហគ្រាស (Electronic Know Your Business - e-KYB)
- បញ្ជាក់ភាពដើមនៃវិក្កយបត្រអេឡិចត្រូនិក ដោយភាពដើមនៃវិក្កយបត្រត្រូវបានរក្សាទុកនៅក្នុងប្រព័ន្ធប្លុកឆេន ដែលអាចធានានូវភាពមិនអាចកែប្រែបាន ហើយបច្ចុប្បន្ននេះរក្សាទុកនៅក្នុងថ្នាល CamDL របស់កម្ពុជា
- ជាស្ពានភ្ជាប់ទំនាក់ទំនងរវាងប្រព័ន្ធគណនេយ្យ ឬប្រព័ន្ធវិក្កយបត្រនានារបស់ភាគីអ្នកលក់ និងភាគីអ្នកទិញ និងភ្ជាប់ទៅកាន់ប្រព័ន្ធរបស់សមាជិកជាអ្នកផ្ដល់សេវា ដើម្បីផ្ដល់លទ្ធភាពផ្លាស់-ប្ដូរទិន្នន័យវិក្កយបត្រជាអេឡិចត្រូនិក
- បញ្ជូនវិក្កយបត្រអេឡិចត្រូនិកពីភាគីអ្នកលក់ ឬអ្នកផ្ដល់សេវា ទៅកាន់ភាគីអ្នកទិញ ឬអ្នកទទួលសេវា។

ខ. សមាជិកជាអ្នកប្រើប្រាស់អាចប្រើប្រាស់មុខងាររបស់ **ប.វ.អ.** តាមរយៈផតថលវិក្កយបត្រអេឡិចត្រូនិក ឬ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានណាមួយរបស់សមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ ដែលបានភ្ជាប់សន្ធានកម្មដោយជោគជ័យជាមួយនឹង **ប.វ.អ.**។

គ. **ប.វ.អ.** អាចនឹងបន្ថែម ឬដកចេញនូវមុខងារណាមួយ ដោយនឹងមានការជូនដំណឹងទៅកាន់សមាជិកទាំងអស់ ក្នុងរយៈពេលយ៉ាងតិច ៣០ (សាមសិប) ថ្ងៃមុនការអនុវត្តការផ្លាស់ប្ដូរនេះ។

ឃ. គ្រប់ប្រតិបត្តិការដែលបានអនុវត្តឆ្លងកាត់ **ប.វ.អ.** នឹងត្រូវចាត់ទុកជាផ្លូវការ និងមិនអាចលុបចេញ ឬកែប្រែបានឡើយ។

### ៤.២. ម៉ោងប្រតិបត្តិការ

ក. **ប.វ.អ.** ដំណើរការ ២៤ម៉ោងជារៀងរាល់ថ្ងៃ លើកលែងតែមានការជូនដំណឹងដោយឡែកពីប្រតិបត្តិករ **ប.វ.អ.**។

ខ. ប្រតិបត្តិករនឹងជូនដំណឹងជាមុនអំពីការផ្អាកប្រតិបត្តិការក្នុងរយៈពេលណាមួយ ដើម្បីជួសជុល ឬធ្វើបច្ចុប្បន្នកម្មប្រព័ន្ធ។

គ. ប្រតិបត្តិកររក្សាសិទ្ធិក្នុងការផ្អាកប្រតិបត្តិការនៅពេលមានបញ្ហា និងមានការចាំបាច់ផ្សេងៗ។

## ផ្នែកទី៥៖ គោលការណ៍សុវត្ថិភាព

ប្រតិបត្តិករ និង សមាជិកនៃ **ប.វ.អ.** ត្រូវគោរពតាមគោលការណ៍សុវត្ថិភាព ដូចខាងក្រោម៖

- ធានានូវភាពសម្ងាត់នៃទិន្នន័យ សុចរិតភាពនៃទិន្នន័យ និងភាពអាចប្រើប្រាស់ទិន្នន័យបានទៅតាមការកំណត់សិទ្ធិប្រើប្រាស់
- រៀបចំប្រព័ន្ធសន្តិសុខឱ្យបានរឹងមាំ សម្រាប់ការពារទិន្នន័យវិក្កយបត្រ និងប្រតិបត្តិការវិក្កយបត្រ ដើម្បីផ្តល់ទំនុកចិត្តដល់អតិថិជន
- រៀបចំជាបណ្តើរៗនូវការធ្វើកូដនីយកម្មលើទិន្នន័យទាំងក្នុងពេលបញ្ជូន និងពេលរក្សាទុក
- ពិនិត្យ និងតាមដានជាប្រចាំទៅលើកំណត់ត្រាប្រើប្រាស់ប្រព័ន្ធ ជាពិសេសការព្យាយាមចូលប្រើប្រាស់ប្រព័ន្ធដែលមិនមានការអនុញ្ញាត
- ត្រួតពិនិត្យ និងវាយតម្លៃលើទិដ្ឋភាពសុវត្ថិភាពនៃប្រព័ន្ធជាប្រចាំ និងត្រូវធ្វើការកែសម្រួល ឬជួសជុលរាល់ចំណុចខ្វះខាតដែលបានរកឃើញ ដែលអាចគំរាមកំហែងដល់សន្តិសុខប្រព័ន្ធ
- ការពារនិងទប់ស្កាត់ឱ្យបាននូវការវាយប្រហារតាមអ៊ីនធឺណិតទៅលើប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួនដែលអាចបណ្តាលឱ្យប៉ះពាល់ដល់ប្រតិបត្តិការនៅក្នុង **ប.វ.អ.**
- សមាជិក **ប.វ.អ.** ត្រូវរាយការណ៍ជាបន្ទាន់ទៅកាន់ប្រតិបត្តិករ **ប.វ.អ.** ក្នុងករណីរកឃើញថាមានភាពមិនប្រក្រតីកើតឡើងដែលអាចបង្កឡើង ឬ/និងប៉ះពាល់ដល់សុវត្ថិភាពនៃ **ប.វ.អ.**
- ប្រសិនបើប្រព័ន្ធរបស់ភាគីណាមួយមានបញ្ហា (ភាគីបង្ក) បង្កផលប៉ះពាល់ដល់ **ប.វ.អ.** និង/ឬប្រព័ន្ធរបស់សមាជិកដទៃទៀត (ភាគីរងការប៉ះពាល់) ភាគីបង្កនិង/ឬភាគីរងការប៉ះ-ពាល់ ត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ប្រតិបត្តិករ **ប.វ.អ.** អំពីបញ្ហា និង/ឬលើកឡើងនូវដំណោះស្រាយ ដើម្បីការពារបន្ថែមលើផ្នែកសុវត្ថិភាពប្រព័ន្ធរបស់ភាគីរងការប៉ះពាល់។

## ផ្នែកទី៦៖ ការថែទាំ និងការដោះស្រាយបញ្ហាបច្ចេកទេស

### ក. ការដោះស្រាយបញ្ហាបច្ចេកទេស

ក្នុងករណីសមាជិកជួបប្រទះបញ្ហាបច្ចេកទេស ឬពិនិត្យឃើញនូវភាពមិនប្រក្រតីលើប្រតិបត្តិការណាមួយនៅក្នុង **ប.វ.អ.** សូមធ្វើការរាយការណ៍ទៅកាន់ប្រតិបត្តិករ **ប.វ.អ.** ជាបន្ទាន់ ដើម្បីប្រតិបត្តិករអាចកំណត់ពីបញ្ហា និងស្វែងរកដំណោះស្រាយទាន់ពេលវេលា។

រាល់ដំណោះស្រាយបញ្ហាបច្ចេកទេសដែលមានការពាក់ព័ន្ធនឹងប្រតិបត្តិការ ឬការតភ្ជាប់ប្រព័ន្ធរបស់សមាជិកជាមួយ **ប.វ.អ.** គឺជាបន្ទុករបស់សមាជិក ដោយសហការ និង សម្របសម្រួលជាមួយប្រតិបត្តិករ **ប.វ.អ.** តាមភាពជាក់ស្តែង និងការចាំបាច់។

### ខ. ការពិនិត្យ តាមដាន និងវាយតម្លៃដំណើរការប្រព័ន្ធ

ក្រុមការងារបច្ចេកទេសនៃ **ប.វ.អ.** នឹងរៀបចំសកម្មភាពពិនិត្យ តាមដាន និងវាយតម្លៃទៅលើកិច្ចដំណើរការរបស់ **ប.វ.អ.** ជាប្រចាំ ឬតាមតម្រូវការជាក់ស្តែង។ សមាជិកត្រូវសហការជាមួយប្រតិបត្តិករ

**ប.វ.អ.** ក្នុងការអនុវត្តសកម្មភាពតាមដាន ពិនិត្យ និងវាយតម្លៃនេះ និងក្នុងករណីពិនិត្យឃើញថាមានបញ្ហាបច្ចេកទេស ឬភាពមិនប្រក្រតីណាមួយ សមាជិកត្រូវទទួលយក និងអនុវត្តតាមការណែនាំរបស់ប្រតិបត្តិករ **ប.វ.អ.**។

**គ. ការកែសម្រួល និងការធ្វើបច្ចុប្បន្នកម្មប្រព័ន្ធ**

សមាជិកនៃ **ប.វ.អ.** នឹងទទួលបានការជូនដំណឹងរាល់ពេលដែល **ប.វ.អ.** ត្រូវបានធ្វើការកែសម្រួល ឬធ្វើបច្ចុប្បន្នកម្ម។ សមាជិកត្រូវទទួលយករាល់ការធ្វើបច្ចុប្បន្នកម្ម និងក្នុងករណីចាំបាច់ សមាជិកអាចស្នើសុំទៅកាន់ប្រតិបត្តិករ ដើម្បីធ្វើការកែសម្រួល ឬធ្វើបច្ចុប្បន្នកម្មប្រព័ន្ធដើម្បីធានាបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃដំណើរការប្រព័ន្ធ។

## ផ្នែកទី៧៖ ការដោះស្រាយវិវាទ

ក. សមាជិកទាំងអស់ត្រូវទទួលស្គាល់ថាការដោះស្រាយវិវាទដោយសន្តិវិធី គឺជាមធ្យោបាយដំបូង និងល្អបំផុត។ ក្នុងន័យនេះ ក្នុងករណីមានវិវាទណាមួយ ភាគីទាំងអស់ចាំបាច់ត្រូវជូនដំណឹងដល់គ្នាទៅវិញទៅមករួមទាំងប្រតិបត្តិករ **ប.វ.អ.** ផងដែរអំពីវិវាទនោះ និងចូលរួមដោយស្មោះត្រង់ក្នុងការពិគ្រោះយោបល់ដើម្បីស្វែងរកដំណោះស្រាយដោយសន្តិវិធី។ ប្រតិបត្តិករ **ប.វ.អ.** ត្រូវបង្កើតឱ្យមានយន្តការអញ្ញាក្រឹត សម្រាប់ទទួល សម្រុះសម្រួល និងចូលរួមដោះស្រាយរាល់វិវាទរបស់សមាជិក។

ខ. ប្រតិបត្តិករ **ប.វ.អ.** មានសិទ្ធិក្នុងការស៊ើបអង្កេតបណ្តឹង ឬវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការលើ **ប.វ.អ.**។ សមាជិកអាចធ្វើការស្នើសុំទៅកាន់ប្រតិបត្តិករ **ប.វ.អ.** នូវរបាយការណ៍ ព័ត៌មាន ឬទិន្នន័យពាក់ព័ន្ធនឹងប្រតិបត្តិការដែលជាកម្មវត្ថុនៃបណ្តឹង ឬវិវាទក្នុងអំឡុងពេលដោះស្រាយបណ្តឹង ឬវិវាទនោះ។ ក្នុងករណីបណ្តឹង ឬវិវាទមិនអាចសម្រុះសម្រួល ឬដោះស្រាយបាន, ប្រតិបត្តិករ **ប.វ.អ.** ត្រូវជូនដំណឹងមកភាគីវិវាទវិញ ដើម្បីឱ្យភាគីទាំងនោះរៀបចំលើកយកវិវាទនោះទៅបន្តដោះស្រាយក្នុងស្ថាប័នមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ផ្អែកលើនីតិវិធីច្បាប់ ដែលមានជាធរមាន។

## ផ្នែកទី៨៖ វិធានទូទៅ

ក. ប្រតិបត្តិករ **ប.វ.អ.** មានឆន្ទានុសិទ្ធិក្នុងការធ្វើវិសោធនកម្មលើវិធាន និង នីតិវិធីនៃការចូលជាសមាជិក **ប.វ.អ.** នេះ តាមការចាំបាច់ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬមធ្យោបាយជូនដំណឹងផ្លូវការនានា។

ខ. រាល់ការទំនាក់ទំនង នឹងត្រូវធ្វើឡើងដោយប្រើប្រាស់ព័ត៌មានទំនាក់ទំនង ដែលបានផ្តល់ឱ្យដោយសមាជិក **ប.វ.អ.** ដូចមានកំណត់ក្នុងវិធាន និង នីតិវិធីនេះ ឬតាមការជូនដំណឹងរបស់ប្រតិបត្តិករតាមរយៈ **ប.វ.អ.**។ ករណីមានការធ្វើបច្ចុប្បន្នភាពព័ត៌មានទំនាក់ទំនង ឬព័ត៌មានផ្ទាល់ខ្លួន សមាជិកនៃ **ប.វ.អ.**

ត្រូវធ្វើការជូនដំណឹង និងស្នើសុំជាមុនមកកាន់ក្រុមការងារប្រតិបត្តិករ **ប.ទ.អ.** ដើម្បីក្រុមការងារធ្វើការកែសម្រួលជូន។

គ. វិធាន និង នីតិវិធីនេះត្រូវបានធ្វើឡើងជាភាសាខ្មែរ និងបកប្រែជាភាសាអង់គ្លេស។ ក្នុងករណីមានខ្លឹមសារផ្ទុយគ្នារវាងឯកសារជាភាសាខ្មែរ និងភាសាដែលបានបកប្រែ ខ្លឹមសារនៅក្នុងភាសាខ្មែរត្រូវមានអានុភាពក្នុងការអនុវត្ត។

## ឧបសម្ព័ន្ធទី១៖ ពាក្យស្នើសុំចូលជាសមាជិក ប.វ.អ. ជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យស្នើសុំចូលជាសមាជិករបស់ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា**
**ជាសមាជិកអ្នកផ្គត់ផ្គង់ប្រព័ន្ធ**

**សូមគោរពជូន**
**ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល**

**កម្មវត្ថុ៖** ការស្នើសុំចូលជាសមាជិករបស់ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គនាយក** មេត្តាជ្រាបថា៖
ក្រុមហ៊ុន.........................................................អក្សរឡាតាំង.......................................................
មានគេហទំព័រក្រុមហ៊ុន.........................................ផ្គត់ផ្គង់ប្រព័ន្ធឈ្មោះ..................................................
អាសយដ្ឋានក្រុមហ៊ុន..........................................................................................................................
លេខអត្តសញ្ញាណកម្មសារពើពន្ធ (អតប)...................................លេខបញ្ជីពាណិជ្ជកម្ម..............................
តំណាងដោយ (ឈ្មោះអ្នកតំណាងស្របច្បាប់របស់ក្រុមហ៊ុន)....................................................................
□អត្តសញ្ញាណបណ្ណ/□លិខិតឆ្លងដែនលេខ....................................លេខទូរសព្ទ.....................................
អ៊ីមែល....................................សូមស្នើសុំចុះឈ្មោះចូលជាសមាជិករបស់ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា ជាសមាជិកអ្នកផ្គត់ផ្គង់ប្រព័ន្ធ។

សូមគោរពភ្ជាប់មកជាមួយនូវ៖

- លិខិតប្រគល់សិទ្ធិ (ក្នុងករណី អ្នកតំណាងមិនមែនជានាយកប្រតិបត្តិឬប្រធានក្រុមហ៊ុន)
- បញ្ជីរាយនាមក្រុមការងារបច្ចេកទេស (សម្រាប់ការងារសន្ទានកម្មជាមួយប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា)
- ឯកសារតម្រូវការផ្លូវច្បាប់ ឯកសារពាក់ព័ន្ធផ្នែកបច្ចេកទេសប្រព័ន្ធ និងឯកសារអំពីព័ត៌មានរបស់ប្រព័ន្ធ (ដើម្បីបញ្ជាក់ពីគុណវុឌ្ឍិក្នុងការស្នើចូលជាសមាជិកប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា)។

ខ្ញុំសូមធានាអះអាងថា៖

- រាល់ព័ត៌មានទាំងអស់ដែលបានបំពេញនៅក្នុងពាក្យស្នើសុំនេះ ពិត និងត្រឹមត្រូវ
- បានផ្តល់ឯកសារពាក់ព័ន្ធ និងគោរពតាមរាល់លក្ខខណ្ឌដូចមានចែងក្នុង "វិធាន និង នីតិវិធីនៃការចូលជាសមាជិក នៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា"
- ពាក្យស្នើសុំត្រូវបានធ្វើឡើងក្នុងដែនសមត្ថកិច្ចរបស់ក្រុមហ៊ុនស្នើសុំ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គនាយក** មេត្តាពិនិត្យ និងសម្រេចតាមការស្នើសុំដោយក្តីអនុគ្រោះ។

ថ្ងៃ ខែ ឆ្នាំ ព.ស.
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ
**នាយកប្រតិបត្តិ/ប្រធានក្រុមហ៊ុន/អ្នកតំណាងស្របច្បាប់**

## ឧបសម្ព័ន្ធទី២៖ ពាក្យស្នើសុំបោះបង់សមាជិកភាពពី ប.វ.អ.

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យស្នើសុំបោះបង់សមាជិកភាពពីប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា**

**សូមគោរពជូន**
**ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល**

**កម្មវត្ថុ** ៖ ការស្នើសុំបោះបង់សមាជិកភាពពីប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា។

**មូលហេតុ** ៖.....................................................................................................................................

.........................................................................................................................................។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងមូលហេតុខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមអគ្គនាយក** មេត្តាជ្រាបថា៖

ក្រុមហ៊ុន.......................................................អក្សរឡាតាំង...................................................
អាសយដ្ឋានក្រុមហ៊ុន.............................................................................................................
លេខអត្តសញ្ញាណកម្មសារពើពន្ធ (អតប).....................................លេខបញ្ជីពាណិជ្ជកម្ម............................
តំណាងដោយ (ឈ្មោះអ្នកតំណាងស្របច្បាប់របស់ក្រុមហ៊ុន)...........................................................
□អត្តសញ្ញាណបណ្ណ/□លិខិតឆ្លងដែនលេខ...................................លេខទូរសព្ទ.......................................
អ៊ីមែល..........................................សូមស្នើសុំបោះបង់សមាជិកភាពពីប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា។

យើងខ្ញុំ យល់ព្រមទទួលយកនូវគ្រប់លក្ខខណ្ឌ ដោយនឹងចូលរួមសហការជម្រះប្រតិបត្តិការដែលនៅសេសសល់ ដោះស្រាយបញ្ហាបច្ចេកទេសតាមការចាំបាច់ និងដោះស្រាយវិវាទនានា ដើម្បីធានាថាការស្នើសុំ បោះបង់សមាជិកភាព មិនប៉ះពាល់ដល់សមាជិកដទៃ និងដំណើរការរបស់ **ប.វ.អ.**។

ខ្ញុំសូមធានាអះអាងថា៖

- រាល់ព័ត៌មានទាំងអស់ដែលបានបំពេញនៅក្នុងពាក្យស្នើសុំនេះ ពិត និងត្រឹមត្រូវ
- ពាក្យស្នើសុំបោះបង់សមាជិកភាពត្រូវបានធ្វើឡើងក្នុងដែនសមត្ថកិច្ចរបស់ក្រុមហ៊ុនស្នើសុំ បានផ្តល់ឯកសារពាក់ព័ន្ធ និងគោរពតាមរាល់លក្ខខណ្ឌរបស់ **ប.វ.អ.**។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គនាយក** មេត្តាពិនិត្យ និងសម្រេចតាមការស្នើសុំដោយក្តីអនុគ្រោះ។

ថ្ងៃ ខែ ឆ្នាំ ព.ស.
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ
**នាយកប្រតិបត្តិ/ប្រធានក្រុមហ៊ុន/អ្នកតំណាងស្របច្បាប់**

## ឧបសម្ព័ន្ធទី៣ ៖ លិខិតប្រគល់សិទ្ធិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

### លិខិតប្រគល់សិទ្ធិ

ក្រុមហ៊ុន.....................................................អក្សរឡាតាំង...................................................
អាសយដ្ឋានក្រុមហ៊ុន.........................................................................................................
លេខអត្តសញ្ញាណកម្មសារពើពន្ធ (អតប)...................................លេខបញ្ជីពាណិជ្ជកម្ម..............................
តំណាងដោយឈ្មោះ.............................................ភេទ........សញ្ជាតិ...............តួនាទី..........................
□អត្តសញ្ញាណបណ្ណ/□លិខិតឆ្លងដែនលេខ.....................................លេខទូរសព្ទ...................................
អ៊ីមែល..............................................សូមធ្វើការប្រគល់សិទ្ធិជូន៖

១. ឈ្មោះ...............................................ភេទ........សញ្ជាតិ...............តួនាទី.........................
អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែនលេខ.............................................លេខទូរសព្ទ.................................
អ៊ីមែល..........................................ជាអ្នកតំណាងស្របច្បាប់របស់ក្រុមហ៊ុន។

ដើម្បី ១) អនុវត្តវិធាន និង នីតិវិធីសម្រាប់ការចុះឈ្មោះចូលជាសមាជិកនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា, ២) ប្រើប្រាស់ផតថលវិក្កយបត្រអេឡិចត្រូនិក, គ្រប់គ្រងព័ត៌មានរបស់ក្រុមហ៊ុន, គ្រប់គ្រងសមាជិករបស់ក្រុមហ៊ុន, ជ្រើសរើសប្រព័ន្ធសម្រាប់ធ្វើប្រតិបត្តិការវិក្កយបត្រអេឡិចត្រូនិក និងធ្វើប្រតិបត្តិការវិក្កយបត្រនៅក្នុងផតថលនេះ និង ៣) អាចចុះហត្ថលេខាលើឯកសារផ្សេងៗពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា ព្រមទាំងធ្វើការចរចាក្នុងនាមជាអ្នកតំណាងឱ្យក្រុមហ៊ុន ដើម្បីទទួលបានសិទ្ធិប្រើប្រាស់ពេញលេញ និងទទួលឯកសារចាំបាច់ (បើមាន)។

| | |
|---|---|
| ថ្ងៃ ខែ ឆ្នាំ ព.ស. | ថ្ងៃ ខែ ឆ្នាំ ព.ស. |
| រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ | រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ |
| **អ្នកប្រគល់សិទ្ធិ** | **អ្នកទទួលសិទ្ធិ** |

# ឧបសម្ព័ន្ធទី៤ ៖ ការធ្វើតេស្តសន្ធានកម្ម (សម្រាប់សមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ)

**Kingdom of Cambodia**

**Nation Religion King**

**Cambodia E-Invoicing System Integration**

***<u>Sample</u>***

System Integration Testing (SIT) or User Acceptance Testing (UAT)

Between Cambodia E-Invoicing System and

(Name of Service Provider)’s System

Date:  DD/MM/YYYY

V1.0
YYYY

## 1. Introduction

1.1. Purpose

[This document outlines the testing process for the system integration between the Cambodia E-Invoicing System and the Service Provider's system. The objective is to validate the compatibility, functionality, and performance of the integrated systems to ensure smooth operation and compliance with technical standards.]

1.2. Scope

[The testing covers all critical integration points, including data exchange, error handling, security, and performance under various scenarios.

## 2. Testing Environment

2.1. Testing Setup and Infrastructure

- Cambodia E-Invoicing System staging/testing environment.
- Service Provider’s testing environment.
- Secure connection for data exchange.

2.2. Test Data Description

- Sample invoices,
- Error scenarios, and
- Security test cases.

## 3. Test Scenarios and Cases

3.1. Test Scenarios

| **Scenario** | **Description** |
|---|---|
| Successful invoice submission | |
| Invalid data submission and error handling | |
| ………………. | |

3.2. Test Cases

| **Case ID** | **Description** | **Input Data** | **Expected Output** | **Status** | **Comments** |
|---|---|---|---|---|---|
| TC001 | Invoice submission | Valid data | Success message | Passed | None |
| … | | | | | |
| … | | | | | |

3.3. Test Execution Plan

- Test preparation: [Date]
- Test execution: [Date]
- Issue resolution: [Date]
- Final validation: [Date]

## 4. Test Results

4.1. Result Summary

- Total test cases executed: [Number]
- Passed: [Number]
- Failed: [Number]
- Issues Identified: [Brief summary]

4.2. Issues Identified and Resolution Status

| **Issue ID** | **Description** | **Status** | **Resolution Timeline** |
|---|---|---|---|
| I001 | Invalid date format | Resolved | [Date] |

[Operator] [Service Provider]

ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា

Cambodia E-Invoicing System

+855 81 881 611

e-invoice@mef.gov.kh

អគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច (BDC), ជាន់ទី ៧,
មហាវិថី OCIC, សង្កាត់ជ្រោយចង្វារ, ខណ្ឌជ្រោយចង្វារ,
រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា